# តើអ្នកត្រូវការជំនួយក្នុង ការទូទាត់វិក្កយបត្រប្រើប្រាស់ការចំណាយ លើទឹក ភ្លើងសំរាមឬ?

**តើអ្នកកំពុងយឺតយ៉ាវ ឬជួបការលំបាកក្នុងការបង់វិក្កយបត្រ Seattle City Light (អគ្គិសនី) ឬ Seattle Public Utilities (ទឹក លូ សំរាម) ទេ?**

យើងនៅទីនេះដើម្បីជួយអ្នក! យើងផ្តល់ជូននូវជម្រើសនៃការសងប្រាក់វិញ និងកម្មវិធីជំនួយវិក្កយបត្រ ដើម្បីជួយអតិថិជនរបស់យើងឱ្យទូទាត់ទាន់ និងបន្តទូទាត់វិក្កយបត្រប្រើប្រាស់របស់ពួកគេបាន។

## ផែនការទូទាត់

### ផែនការទូទាត់ថ្លៃសេវា ទឹក ភ្លើង លូ សំរាមរបស់ Seattle City Light និង Seattle Public Utilities

ប្រសិនបើវិក្កយបត្ររបស់អ្នកហួសកំណត់ជាមួយ Seattle City Light (អគ្គិសនី) ឬ Seattle Public Utilities (ទឹក/លូ/សំរាម) យើងផ្តល់ជូនផែនការទូទាត់ដល់អតិថិជនលំនៅដ្ឋាន និងអាជីវកម្មទាំងអស់។ ផែនការទូទាត់អនុញ្ញាតឱ្យអ្នកបង់សមតុល្យរបស់អ្នកក្នុងចំនួនតិចជាងមុន និងអាចគ្រប់គ្រងបានតាមពេលវេលា។

## កម្មវិធីជំនួយវិក្កយបត្រ

ប្រសិនបើអ្នកជាអតិថិជនលំនៅដ្ឋាន ហើយបំពេញតាមតម្រូវការប្រាក់ចំណូល អ្នកអាចមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ជំនួយវិក្កយបត្រដែលកំពុងដំណើរការ និងជំនួយវិក្កយបត្របន្ទាន់។

## កម្មវិធីបញ្ចុះតម្លៃ ទឹក ភ្លើង លូ សំរាម

អតិថិជនដែលមានសិទ្ធិទទួលបានតាមប្រាក់ចំណូលអាចចុះឈ្មោះក្នុងកម្មវិធីបញ្ចុះតម្លៃសេវាប្រើប្រាស់របស់ទីក្រុង Seattle ដែលផ្តល់នូវការបញ្ចុះតម្លៃ 60% លើវិក្កយបត្រ Seattle City Light និងការបញ្ចុះតម្លៃ 50% លើវិក្កយបត្រប្រើប្រាស់ Seattle Public Utilities ពេលអនាគត។

## កម្មវិធីជំនួយវិក្កយបត្របន្ទាន់

### Seattle City Light

ប្រសិនបើអ្នកកំពុងពន្យាពេលការទូទាត់វិក្កយបត្រអគ្គិសនី និងមានហានិភ័យអាចរងការផ្តាច់ភ្លើង កម្មវិធីជំនួយវិក្កយបត្របន្ទាន់របស់ Seattle City Light អាចជួយអ្នកបាន។ អតិថិជនដែលមានគ្រប់លក្ខខណ្ឌតាមប្រាក់ចំណូលអាចទទួលបានរហូតដល់ $710 ក្នុងមួយឆ្នាំតាមប្រតិទិនក្នុងជំនួយសង្គ្រោះបន្ទាន់ ដើម្បីកាត់បន្ថយសមតុល្យហួសកាលកំណត់របស់ពួកគេ។ គ្រួសារដែលមានកូនអាយុក្រោម 18 ឆ្នាំអាចមានសិទ្ធិទទួលបានជំនួយរហូតដល់ $1,420 ក្នុងមួយឆ្នាំតាមប្រតិទិន។

### Seattle Public Utilities

ប្រសិនបើអ្នកកំពុងយឺតយ៉ាវក្នុងការទូទាត់វិក្កយបត្រ ទឹក/លូ/សំរាម ហើយមានហានិភ័យអាចរងការផ្តាច់សេវាទាំងនេះ កម្មវិធីជំនួយបន្ទាន់របស់ Seattle Public Utilities អាចជួយអ្នកបាន។ អតិថិជនដែលមានគ្រប់លក្ខខណ្ឌប្រាក់ចំណូលអាចទទួលបានរហូតដល់ $518 ក្នុងមួយឆ្នាំ ដើម្បីជួយទូទាត់សមតុល្យហួសកាលកំណត់របស់ពួកគេ។ គ្រួសារដែលមានកូនអាយុក្រោម 18 ឆ្នាំអាចទទួលបានរហូតដល់ $1,036 ក្នុងមួយឆ្នាំតាមប្រតិទិន។

# ទំនាក់ទំនងជាមួយយើង

ប្រសិនបើអ្នកបានយឺតយ៉ាវក្នុងការទូទាត់វិក្កយបត្រសេវាប្រើប្រាស់ ឬកំពុងជួបការលំបាកក្នុងការទូទាត់ជារៀងរាល់ខែ យើងអាចធ្វើការជាមួយអ្នកក្នុងការរៀបចំផែនការទូទាត់ និងដើម្បីស្នើសុំជំនួយបង់វិក្កយបត្រ ដូច្នេះហើយអ្នកអាចរក្សាសេវាប្រើប្រាស់របស់អ្នក។

## សូមមើលគេហទំព័រតាមអនឡាញ

សូមមើលគេហទំព័រ seattle.gov/UtilityBillHelp ដើម្បីរៀបចំផែនការទូទាត់ ចុះឈ្មោះសម្រាប់ជំនួយវិក្កយបត្រ និងទូទាត់សមតុល្យរបស់អ្នក។

## ទូរសព្ទទៅក្រុមសេវាកម្មអតិថិជនរបស់យើង

ទូរសព្ទមកយើងតាមរយៈលេខ (206) 684-3000 (ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 7:30 ព្រឹក ដល់ 6:00 ល្ងាច) ដើម្បីទូទាត់ប្រាក់ពិភាក្សាជាមួយអ្នកតំណាងអំពីការបង្កើតផែនការទូទាត់ ឬស្នើសុំកម្មវិធីជំនួយវិក្កយបត្រ។ ប្រសិនបើអ្នកត្រូវការជំនួយជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស ក្រុមសេវាកម្មអតិថិជនរបស់យើងនឹងជួយអ្នកដោយមិនគិតថ្លៃតាមភាសាដែលអ្នកពេញចិត្ត។

## សូមទៅកាន់មជ្ឈមណ្ឌលសេវាកម្មអតិថិជនរបស់យើង

សូមទៅកាន់មជ្ឈមណ្ឌលសេវាកម្មអតិថិជន ដើម្បីទូទាត់វិក្កយបត្ររបស់អ្នកដោយផ្ទាល់ដោយសាច់ប្រាក់ សែក ឬបណ្ណកណទាន។

**មជ្ឈមណ្ឌលសេវាកម្ម Seattle City Light North**
1300 N 97th Street, Seattle, WA 98103 | ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 7:30 ព្រឹក ដល់ 4:30 រសៀល| (206) 615-0600

**មជ្ឈមណ្ឌលសេវាកម្ម Seattle City Light South**
3613 4th Avenue S, Seattle, WA 98134 | ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 8:30 ព្រឹក ដល់ 4:30 រសៀល | (206) 386-4200

**មជ្ឈមណ្ឌលសេវាកម្ម Ballard**
5604 22nd Ave NW, Seattle, WA 98107 | ចាប់ពីថ្ងៃអង្គារ ដល់ថ្ងៃសុក្រ ពីម៉ោង 9 ព្រឹក ដល់ 5 ល្ងាច| (206) 684-4060

**មជ្ឈមណ្ឌលសេវាកម្ម Central District**
464 12th Avenue, First Fl, Seattle, WA 98122 | ចាប់ពីថ្ងៃអង្គារ ដល់ថ្ងៃសុក្រ ពីម៉ោង 9 ព្រឹក ដល់ 5 ល្ងាច | (206) 684-4767

**មជ្ឈមណ្ឌលសេវាកម្ម Downtown**
700 Fifth Avenue, Seattle, WA 98104 | ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 8:30 ព្រឹក ដល់ 4 រសៀល | (206) 684-3000

**មជ្ឈមណ្ឌលសេវាកម្ម Lake City**
12525 28th Ave NE, 2nd Fl, Seattle, WA 98125 | ចាប់ពីថ្ងៃអង្គារ ដល់ថ្ងៃសុក្រ ពីម៉ោង 9 ព្រឹក ដល់ 5 ល្ងាច | (206) 684-7526

**មជ្ឈមណ្ឌលសេវាកម្ម Southeast**
3815 S Othello St, Suite 105, Seattle, WA 98118 | ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសៅរ៍ ពីម៉ោង 9 ព្រឹក ដល់ 5 ល្ងាច | (206) 386-1931

**មជ្ឈមណ្ឌលសេវាកម្ម Southwest**
2801 SW Thistle St, Seattle, WA 98126 | ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 9 ព្រឹក ដល់ 5 ល្ងាច| (206) 684-7417

**មជ្ឈមណ្ឌលសេវាកម្ម University**
4534 University Way NE, Seattle, WA 98105 | ចាប់ពីថ្ងៃអង្គារ ដល់ថ្ងៃសៅរ៍ ពីម៉ោង 9 ព្រឹក ដល់ 5 ល្ងាច | (206) 684-7542